ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ភ្នំពេញ ថ្ងៃទី ០៨ ខែវិច្ឆិកា ឆ្នាំ២០១៦

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

# កិច្ចប្រជុំបូកសរុបលទ្ធផលប្រមូលចំណូលពន្ធ ប្រចាំខែតុលា ឆ្នាំ២០១៦




© *រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ*

នាវេលាម៉ោង ០៨:៣០ នាទីព្រឹក ថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៦ នៅអគ្គនាយកដ្ឋានពន្ធដារ មានរៀបចំកិច្ចប្រជុំបូកសរុប លទ្ធផលគ្រប់គ្រងប្រមូលចំណូលពន្ធ ប្រចាំខែតុលា ឆ្នាំ២០១៦ របស់អគ្គនាយកដ្ឋានពន្ធដារ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ ព្រមទាំងវត្តមានចូលរួមរបស់ ឯកឧត្តមអគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារ លោកប្រធាន-អនុប្រធាននាយកដ្ឋាន លោកប្រធានសាខាពន្ធដារខេត្ត-ខណ្ឌទាំងអស់ ក្រោមចំណុះអគ្គនាយកដ្ឋានពន្ធដារ។

ជាកិច្ចចាប់ផ្តើមឯកឧត្តម គង់វិបុលប្រតិភូរាជរដ្ឋាភិបាល និងជាប្រធានអង្គប្រជុំ បានសម្តែងនូវកិច្ចស្វាគមន៍យ៉ាងកក់ក្តៅចំពោះវត្តមានឯកឧត្តមអគ្គនាយករង លោក-លោកស្រី មន្ត្រីរាជការពន្ធដារទាំងអស់ដែលបានចូលរួមក្នុងកិច្ចប្រជុំ នាព្រឹកនេះ និងសូមសម្តែងនូវការអរគុណ ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំ និងមន្ត្រីពន្ធដារគ្រប់លំដាប់ថ្នាក់ដែលបានខិតខំប្រឹងប្រែងប្រមូលចំណូលពន្ធ រហូតសម្រេចបានលទ្ធផលគួរជាទីមោទនៈ។

ជាលទ្ធផល ក្នុងខែតុលា ឆ្នាំ២០១៦ ចំណូលពន្ធ-អាករគ្រប់ប្រភេទដែលអគ្គនាយកដ្ឋានពន្ធដារប្រមូលបាន មានចំនួន ៤៩៦ ១៤៦, ៤៧ លានរៀល (ប្រមាណជា ១២៤,០៣ លានដុល្លារ)។ សម្រាប់រយៈពេល ១០ ខែ ឆ្នាំ២០១៦ ចំណូលពន្ធ-អាករសរុបដែលប្រមូលបាន មានចំនួន ៥ ២៦១ ១៨៦,៤៨




© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ

លានរៀល (ប្រមាណ ១ ៣១៥,២៩ លានដុល្លារ) ស្មើនឹង ៩២,៥២% នៃគោលដៅកំណត់ដោយច្បាប់។

ប្រសិនបើប្រៀបធៀបនឹងរយៈពេលដូចគ្នា នៃឆ្នាំ២០១៥ ឃើញថា ការប្រមូលចំណូលពន្ធ-អាករគ្រប់ប្រភេទ សម្រាប់រយៈពេល ១០ ខែ ឆ្នាំ២០១៦ កើនឡើងចំនួន ៩០៦ ២១០,២១ លានរៀល (ប្រមាណជា ២២៦,៥៥ លានដុល្លារ) ឬស្មើនឹងអត្រាកំណើន ២០,៨១ %។

ក្នុងរយៈពេលដូចគ្នានេះ អគ្គនាយកដ្ឋានពន្ធដារសង្កេតឃើញថា មានការកើនឡើងផងដែរ នូវចំណូលពន្ធ-អាករ តាមប្រភេទពន្ធ និងសកម្មភាពអាជីវកម្មសំខាន់ៗមួយចំនួន ដូចជា ៖ ពន្ធលើប្រាក់ចំណេញ កើនឡើង ១៩,១%, ពន្ធលើប្រាក់បៀវត្ស កើនឡើង ២៤,៩%,អាករលើតម្លៃបន្ថែម កើនឡើង ២២,៩%, និងអាករពិសេស កើនឡើង ២៦,១%។ ចំណែកឯចំណូលពន្ធ-អាករ តាមសកម្មភាពអាជីវកម្ម ក៏មានការកើនឡើងស្ទើរគ្រប់ប្រភេទអាជីវកម្មផងដែរ។

ឆ្លៀតក្នុងឱកាសនេះដែរ ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល ប្រធានអង្គប្រជុំ បានផ្តល់នូវអនុសាសន៍ណែនាំដល់អង្គភាពពន្ធដារក្រោមឱវាទទាំងអស់ ឲ្យបន្តកិច្ចខិតខំប្រឹងប្រែងក្នុងការប្រមូលចំណូលពន្ធ ជាពិសេស ផ្តោតជាសំខាន់លើកិច្ចការមួយចំនួនដូចខាងក្រោម ៖

- បន្តអនុវត្តប្រកបដោយប្រសិទ្ធភាពខ្ពស់ នូវយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម របស់រាជរដ្ឋាភិបាល និងកម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈ

- បន្តជំរុញការគ្រប់គ្រង និងផ្សព្វផ្សាយការធ្វើបច្ចុប្បន្នភាពអចលនទ្រព្យសម្រាប់ពន្ធលើអចលនទ្រព្យ និងពង្រឹងការប្រមូលពន្ធប្រភេទនេះសម្រាប់ឆ្នាំ២០១៦ ក៏ដូចជាឆ្នាំបន្តបន្ទាប់ខាងមុខឲ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ថែមទៀត តាមរយៈការបង្កើនកិច្ចសហការជាមួយអាជ្ញាធរដែនដី នៅថ្នាក់មូលដ្ឋាន ដោយដាក់មន្ត្រីពន្ធដារឲ្យប្រចាំ ការនៅតាមអាជ្ញាធរស្រុក-ខណ្ឌ-ក្រុង នីមួយៗ ដើម្បីធ្វើការកត់ត្រានូវទិន្នន័យអចលនទ្រព្យដែលស្ថិតក្នុងដែនដីរដ្ឋបាល សម្រាប់ធ្វើការផ្ទៀងផ្ទាត់ទិន្នន័យអចលនទ្រព្យ ដែលបាននិងមិនទាន់បានប្រកាសបង់ពន្ធ

- បន្តចុះអង្កេតស្រាវជ្រាវសហគ្រាស (Street Survey) ក្នុងខណ្ឌទួលគោក ខណ្ឌដូនពេញ និងបណ្តាខណ្ឌនានាក្នុងរាជធានីភ្នំពេញ ជាបន្តបន្ទាប់ ដើម្បីឲ្យសហគ្រាសដែលមិនបានចុះបញ្ជីត្រឹមត្រូវ ឬមិនព្រមមកចុះបញ្ជីពន្ធដារ ឲ្យមកចុះបញ្ជីពន្ធដារបានគ្រប់គ្នា

- ពង្រឹងការដាក់លិខិតប្រកាស នៅនាយកដ្ឋានថ្នាក់កណ្តាល ក៏ដូចជាតាមសាខាពន្ធដារខេត្ត-ខណ្ឌនីមួយៗ

- បន្តពង្រឹងការធ្វើសវនកម្មលើសហគ្រាស ជាពិសេសសហគ្រាសដែលប្រកាសពន្ធទាប មិនសមស្របនឹងស្ថានភាពជាក់ស្តែងនៃអាជីវកម្មរបស់ខ្លួន

- ពិនិត្យ ផ្ទៀតផ្ទាត់ឲ្យបានម៉ត់ចត់ ចំពោះការស្នើសុំបង្វិលសង របស់សហគ្រាសនានា តាមរយៈការពង្រឹង ការអនុវត្តការប្រើប្រាស់វិធានវិក្កយបត្រ ដែលអគ្គនាយកដ្ឋានពន្ធដារបានដាក់ចេញកន្លងមក

- យកចិត្តទុកដាក់ខ្ពស់ចំពោះការស្នើសុំផ្ទេរសហគ្រាស ដោយត្រូវអនុវត្តតាមសេចក្តីណែនាំដែលកំពុងមានជាធរមាន

- ពង្រឹងការគ្រប់គ្រងធនធានមនុស្ស និងពង្រឹងសមត្ថភាពមន្ត្រី ដើម្បីក្លាយជាមន្ត្រីដែលពោរពេញដោយសមត្ថភាព ជំនាញ និងទេពកោសល្យ ព្រមទាំងប្រើឲ្យបាន



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ

អស់សក្តានុពល នូវធនធានមន្ត្រី ដែលមានស្រាប់។ ព្រមជាមួយនេះ អគ្គនាយកដ្ឋានពន្ធដារក៏កំពុងរៀបចំកម្មវិធីគ្រប់គ្រងធនធានមនុស្សតាមប្រព័ន្ធបច្ចេកវិទ្យា ដោយធ្វើការប្រមូលផ្តុំនូវប្រវត្តិការងារ និងស្នាដៃផ្សេងៗដែលមន្ត្រីគ្រប់រូបសម្រេចបាន ដើម្បីធ្វើជាមូលដ្ឋានក្នុងការវាយតម្លៃការងារ។ កម្មវិធីនេះ គ្រោងនឹងដាក់ឲ្យដំណើរការនៅដើមឆ្នាំ២០១៧ ខាងមុខ

- រៀបចំអភិវឌ្ឍកម្មវិធីសវនកម្មសហគ្រាស តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ក្នុងការជ្រើសរើសសហគ្រាសដើម្បីធ្វើសវនកម្ម ដែលកម្មវិធីនេះគ្រោងនឹងដាក់ឲ្យដំណើរការនៅដើមឆ្នាំ២០១៧ ខាងមុខនេះផងដែរ។
- បន្តធ្វើទំនើបកម្មប្រព័ន្ធព័ត៌មានវិទ្យា រៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យ (Data Base) ដែលមានលក្ខណៈល្អប្រសើរ ដើម្បីងាយស្រួលក្នុងការគ្រប់គ្រងប្រមូលចំណូលពន្ធ
- បន្តលើកកម្ពស់និងបញ្ជ្រាបវប្បធម៌ពន្ធដារ បន្តពង្រឹងការអនុវត្តច្បាប់ស្តីពីសារពើពន្ធ ក្នុងចំណោម ធុរជនគ្រប់មជ្ឈដ្ឋាន តាមរយៈការរៀបចំសិក្ខាសាលាផ្សព្វផ្សាយ ស្តីពីប្រព័ន្ធពន្ធដារកម្ពុជា

ជាទីបញ្ចប់ ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល ប្រធានអង្គប្រជុំ បានវាយតម្លៃខ្ពស់ និងថ្លែងនូវអំណរគុណយ៉ាងជ្រាលជ្រៅចំពោះថ្នាក់ដឹកនាំ គ្រប់អង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានពន្ធដារ ដែលបាននិងកំពុងចូលរួមយ៉ាងសកម្មក្នុងការខិតខំប្រឹងប្រែងប្រមូលចំណូល រហូតទទួលបានលទ្ធផលយ៉ាងល្អប្រសើរ ដែលនេះគឺជាជោគជ័យរួមរបស់អគ្គនាយកដ្ឋានពន្ធដារ ព្រោះថា ប្រសិនបើមិនមានការចូលរួមពីគ្រប់អង្គភាពពាក់ព័ន្ធ លទ្ធផលប្រមូលចំណូលពន្ធនេះ នឹងមិនអាចសម្រេចទៅប្រកបដោយលទ្ធផលត្រចះត្រចង់បែបនេះបានទេ។ ទន្ទឹមនោះ ឯកឧត្តមប្រធានអង្គប្រជុំ ក៏បានផ្តល់ការណែនាំបន្ថែមដល់គ្រប់អង្គភាព ឲ្យបន្តខិតខំពង្រឹងការអនុវត្តច្បាប់ វិន័យការងារ និងត្រូវមានភាពទន់ភ្លន់តែម៉ឺងម៉ាត់ផ្អែកទិដ្ឋភាពច្បាប់ ក្នុងការឆ្លើយតបទៅកាន់អ្នកជាប់ពន្ធ ធ្វើយ៉ាងណាឲ្យអ្នកជាប់ពន្ធសប្បាយចិត្ត មិនសម្តែងការរអ៊ូរទាំ និងផ្តល់កិច្ចសហការល្អក្នុងការបង់ពន្ធជូនរដ្ឋ៕



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ